

# MY BELOVED

## Kim Hak

## មាតុភូមិជាទីស្នេហា៖ គឹម ហាក់

**2–17 November 2024　BankART Station**

主催：Rei Foundation Limited　会期：2024年11月2日(土)–11月17日(日)11:00–19:00　会場：BankART Station　会期中無休　入場無料
Organized by Rei Foundation Limited　Exhibition Period: Thursday, July 4, 2024 - Monday, September 23, 2024 (11:00 am to 7:00 pm)
Venue: BankART Station　Open every day throughout the exhibition period.　Fee: Free of charge

Rei Foundation Limited

  

## មាតុភូមិជាទីស្នេហា

ប្រទេសកម្ពុជា មានអ្វីច្រើនយ៉ាង លើសពីអ្វីដែលគេធ្លាប់តែគិតជាទូទៅ ពីរូបភាពនៃប្រាសាទអង្គរវត្ត និងរបបខ្មែរក្រហម។ «មាតុភូមិជាទីស្នេហា» គឺជាការឆ្លើយតបតាមរយៈរូបថតចំពោះគំនិតដែលបានគិតទុកជាមុនអំពីប្រទេសនេះ។ ទីនេះជាកន្លែងដែលខ្ញុំកើត និងធំដឹងក្តីឡើង។ មាតុភូមិ ជាទឹកដីដែលផ្តល់ជីវិតដល់ខ្ញុំ ហើយក៏មានសិល្បៈ និងវប្បធម៌សម្បូរបែប ព្រមទាំងមនុស្សម្នាល្អៗ និងធម្មជាតិដ៏ស្រស់ស្អាតជាច្រើន។

អស់រយៈពេល៧ឆ្នាំ គិតចាប់ពីឆ្នាំ២០០៣ មុនពេលដែលខ្ញុំប្រឡូកខ្លួនទាំងស្រុងចូលទៅក្នុងវិស័យថតរូប ខ្ញុំបានធ្វើដំណើរគ្រប់ទីកន្លែងទូទាំងប្រទេសកម្ពុជា នៅពេលបំពេញការងារក្នុងឧស្សាហកម្មទេសចរណ៍។ រយៈពេលនោះរួមមាន ២ឆ្នាំ ធ្វើការជាមួយក្រុមបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរានៅក្នុងរមណីយដ្ឋានអង្គរ និង៥ឆ្នាំជាមួយទីភ្នាក់ងារទេសចរណ៍នៅរាជធានីភ្នំពេញ។ ចំណេះដឹងអំពីប្រទេសនេះ គឺមានតម្លៃមិនអាចកាត់ថ្លៃបាន ខណៈពេលដែលក្នុងឆ្នាំ២០១២  ខ្ញុំចាប់ផ្តើមធ្វើដំណើរលក្ខណៈផ្ទាល់ខ្លួន ដោយតែម្នាក់ឯង ជាមួយមិត្តភក្តិជិតស្និទ្ធ និងក្រុមគ្រួសារ ពាសពេញផ្ទៃប្រទេសដើម្បីថតរូបភាពចម្រុះនានា ថតរូបទេសភាពបណ្តាខេត្តតាមដងទន្លេមេគង្គ  រាជធានីភ្នំពេញ ខេត្តជុំវិញបឹងទន្លេសាបដ៏ធំល្វឹងល្វើយ និងចុះទៅតាមភាគខាងត្បូងដល់សមុទ្រ និងខេត្តនានានៅជាប់មាត់សមុទ្រ។ ខ្ញុំឃើញភាពស្រស់ស្អាតជាសកលមួយប្រកប ដោយភាពទន់ភ្លន់ ដែលធម្មជាតិបង្កើតឡើង ដោយសកម្មភាពនានារបស់មនុស្ស និងពីលំហូរនៃពេលវេលា ដែលទេសភាពក្នុងប្រទេសកម្ពុជាផ្លាស់ប្តូរឥតឈប់ឈរ។ តាំងពីពេលដំបូង ដែលខ្ញុំចាប់ផ្តើមធ្វើការងារលើគម្រោងនេះ ខ្ញុំសម្រេចចិត្តថតរូបតែពេលព្រឹកព្រលឹមតែប៉ុណ្ណោះ ដើម្បីទទួលបានពន្លឺស្រទន់ពីព្រះអាទិត្យ ហើយខ្ញុំយល់ឃើញថាថ្ងៃរះជានិមិត្តរូបនៃការចាប់ផ្តើមរូបភាពថ្មីមួយនៃប្រទេសកម្ពុជា។ កម្រងរូបថតពីការធ្វើដំណើរអស់ទាំងនេះតែងតែថតឡើងដោយភាពជាក់លាក់ និងប្រាកដប្រជាបំផុត ទាំងការចាប់ប្លង់ និងកំណត់ពណ៌ដោយគ្មានការថែមថយពណ៌ឬពន្លឺ គឺដើម្បីតែរំលេចភាពសម្បូរបែប និងភាពចម្រុះនៃទេសភាពរបស់ប្រទេសកម្ពុជា។ ការផលិតស្នាដៃនេះចំណាយពេលវេលាអស់រយៈពេល១០ឆ្នាំ ហើយខ្ញុំសង្កេតឃើញថាកន្លែងមួយចំនួនបានបាត់បង់ ឬផ្លាស់ប្តូររូបរាងគួរឱ្យកត់សម្គាល់ ដោយសារការអភិវឌ្ឍយ៉ាងគំហុក និងការសាងសង់សំណង់ផ្សេងៗក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។

«មាតុភូមិជាទីស្នេហា» ជាការធ្វើដំណើរលក្ខណៈផ្ទាល់ខ្លួន ជាមួយនឹងការថតរូបដោយប្រើហ្វីល និងអមជាមួយសំបុត្រស្នេហាមួយច្បាប់ទៅកាន់ប្រទេសកំណើតរបស់ខ្ញុំ។ សំបុត្រនេះបង្ហាញពីអារម្មណ៍ និងមនោសញ្ចេតនាផ្ទាល់ខ្លួនរបស់ខ្ញុំចំពោះទីកន្លែងនានាដែលខ្ញុំបានទៅដល់ដើម្បីថតរូប។ ទីកន្លែងនីមួយៗ ខ្ញុំចំណាយពេលដើម្បីទទួលយកបរិយាកាស ស្រូបយកខ្យល់អាកាស និងទទួលអារម្មណ៍ពីធម្មជាតិ និងពីមនុស្សម្នាទាំងឡាយដែលខ្ញុំថត។ នោះដូចជាការហែកស្រោមសំបុត្រដោយប្រុងប្រយ័ត្ន ដើម្បីបើកយកសំបុត្រពីខាងក្នុងចេញមក។ បំណងរបស់ខ្ញុំចំពោះការងារនេះ គឺចង់បង្ហាញពីលំហូរដ៏ទន់ភ្លន់នៃពេលវេលា និងពណ៌ចម្រុះដ៏សម្បូរបែបនៃប្រទេសកម្ពុជាទៅកាន់ពិភពលោក។

ការធ្វើដំណើរថតរូបទៅកាន់ទឹកដីដែលមានមនុស្សជំនាន់ថ្មីអាចសង្ឃឹម និងសុបិន។

កម្ពុជា ២០១២ - ២០២២

**គឹម ហាក់** (កើតឆ្នាំ ១៩៨១) នាខេត្តបាត់ដំបង ភាគពាយ័ព្យនៃប្រទេសកម្ពុជា

កើតពីរឆ្នាំ ក្រោយការដួលរលំនៃរបបខ្មែរក្រហម លោកធំក្តីឡើង ឮការចងចាំពីឪពុកម្តាយរបស់លោក។
បន្ថែមពីលើការងារ "រស់រាន . **Alive**" ដែលជាគម្រោងចងចាំ បង្កើតឡើងវិញ និងបកស្រាយឡើងវិញនូវប្រវត្តិសាស្ត្រសង្គមរបស់ប្រទេសកម្ពុជា
មុន និងក្រោយរបបខ្មែរក្រហម។ លោកថតរូប និងកត់ត្រាអនុស្សាវរីយ៍នៃទឹកដី អគារនានា និងការផ្លាស់ប្តូរទេសភាពនៃមាតុភូមិកំណើតរបស់លោក
ហើយមានបំណងកែលម្អរចនាសម្ព័ន្ធនយោបាយ និងវប្បធម៌នៃប្រទេសកម្ពុជា។

ស្វែងយល់បន្ថែមអំពីលោក **https://www.kimhak.com/biography/**

## My Beloved

カンボジアというとたいていの人はアンコール・ワットやクメール・ルージュというイメージを持っていますが、この国にはそれを遙かに超えるものがあります。「My Beloved」はこのイメージに対する私のこたえなのです。私はここで生まれ育ちました。私に命を授け、豊かな芸術と文化があり、美しい人々が暮らし、自然に恵まれた土地なのです。

写真家として専念し始める前の2003年から7年間、私は旅行業界で働きながらカンボジアの各地を旅しました。この間の2年間、アンコール遺跡でアプサラ機構の考古学チームと過ごし、5年間プノンペンの旅行会社で働きました。この経験から、自分の国について学び、その後の旅に役に立つ貴重な知識を得ました。2012年に個人的な旅に出て、一人で、あるいは親しい友人や家族と一緒に全国各地を旅し、多様な写真を撮りました。メコン川沿い、トンレ・サップ湖周辺、首都プノンペン、南部の海へ行き海岸沿いの州も訪れて、様々な風景を記録しました。カンボジアの変わり続ける風景の中に、自然、人の営み、時の流れによって作られた普遍的で穏やかな美しさを私は発見しました。このプロジェクトに取り組み始めた時から、撮影する時間帯を早朝のみに絞りました。その方が明かりが柔らかく、また夜明けをカンボジアの新しいイメージ誕生の象徴ととらえたのです。この個人的な旅のアルバムでは、常に精密なフレーミングを行い、一切加工しない色がカンボジアの風景の豊かさと多様性を繊細に照らし出しています。この創作活動には10年を費やし、カンボジアの近年の急速な変動や都市開発のために失われた場所や大きく変化した場所を、私は目撃する事ができました。

「My Beloved」はアナログ写真による個人的な旅路であり、私の母国に贈るラブレターです。撮影した場所に対する私の感情と感傷的な思いを表しています。それぞれの場所で、その雰囲気を吸収し、空気を吸い、被写体である自然と人の感触を余すことなく感じ取るために時間をかけました。慎重に封筒を開けて中から大切な手紙を取り出す時のように、カンボジアの穏やかな時の流れと豊かな色彩を世界に伝えるのが、この仕事における私の意図です。

新しい世代が希望と夢を持つ事ができる大地を巡る写真の旅

カンボジア、2012–2022

キム・ハク（1981年生まれ）カンボジアの北西部に位置するバッタンバン市出身。
クメール・ルージュ政権崩壊の2年後に生まれ、両親から当時の記憶を聞いて育つ。クメール・ルージュ政権前後のカンボジアの社会史を記憶・再生・再解釈するプロジェクト「Alive」をはじめ、土地や建物の記憶や変化する祖国の風景を撮影して記録し、カンボジアの政治的文化的構造に関連するテーマを探求している。https://www.kimhak.com/biography/

### MY BELOVED: Kim Hak



発行：Rei Foundation Limited
B4変形、上製本、246頁
カンボジアの伝統的な布（クロマー）の布貼り
価格：未定
刊行：2024年11月2日
装丁：林琢真
編集：Rei Foundation Limited
印刷：ライブアートブックス

**BankART Station**
横浜市西区みなとみらい5-1 新高島駅 B1F
Shin-Takashima Station B1F, 5-1 Minatomirai, Nishi-ku, Yokohama, Kanagawa